**មាត្រា ៤ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០០

## ២- សេចក្តីសំរេច

### សេចក្តីសំរេចលេខ ៦១ សសរ

### ស្តីពីការបាត់តាំងគ្នាក់ងារប្រតិបត្តិ ដើម្បីសំរបសំរួលជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងកិច្ចការហិរញ្ញប្បទាន សំរាប់សង្គ្រោះបន្ទាន់ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ ឆ្នាំ ២០០០

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់ និងបន្ទាន់ចំពោះមុខ

**សំរេច**

**ប្រការ ១ :**

តាំងតាំងភ្នាក់ងារប្រតិបត្តិមួយ ដើម្បីសំរបសំរួលជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងកិច្ចការហិរញ្ញប្បទានសំរាប់សង្គ្រោះបន្ទាន់ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ឆ្នាំ ២០០០ ដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម នាយ ចន រដ្ឋមន្ត្រីក្រសួងផែនការ ប្រធាន
២-ឯកឧត្តម សុស សារមេត ឧត្តមទីប្រឹក្សាសេដ្ឋកិច្ច រាជរដ្ឋាភិបាល ទីប្រឹក្សា
៣-ឯកឧត្តម ស៊ី ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
៤-ឯកឧត្តម អ៊ុក រ៉ាប៊ុន
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
៥-ឯកឧត្តម អ៊ី ឌិមហាន រដ្ឋលេខាធិការក្រសួងផែនការ សមាជិកអចិន្ត្រៃយ៍
៦-ឯកឧត្តម ម៉ុន អ៊ុយ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៧-ឯកឧត្តម ឈឿង យ៉ាណារ៉ា អគ្គលេខាធិការ គជនា សមាជិក

**ប្រការ ២ :**

ភ្នាក់ងារប្រតិបត្តិនេះ មានភារកិច្ច :

១-សហការជាមួយអ្នកជំនាញការជាន់ខ្ពស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការចុះសិក្សា និងវាយតំលៃលំអិតនូវការខូចខាតលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ដែលទទួលការខូចខាតដោយសារទឹកជំនន់ ដើម្បីរៀបចំគំរោងផែនការ សំរាប់ស្តារ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធឡើងវិញ
២-សំរបសំរួលការងាររបស់អ្នកជំនាញការជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលមកគ្រប់គ្រងជំរុញ និងតាមដាន ការអនុវត្តន៍គំរោងទាំងអស់នេះ
៣-សំរបសំរួលជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសជាមួយក្រសួងដែលមានគំរោងកម្មវិធីសំរាប់ប្រើប្រាស់ហិរញ្ញប្បទានសំរាប់សង្គ្រោះបន្ទាន់នេះ
៤-ធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការអនុវត្តន៍ការប្រើប្រាស់ហិរញ្ញប្បទាន សំរាប់សង្គ្រោះបន្ទាន់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការអនុវត្តន៍គំរោងទាំងអស់នេះ តាមដំណាក់កាលនីមួយៗ ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :**

ភ្នាក់ងារប្រតិបត្តិនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយសំរាប់ជំនួយការងារ ដែលមានទីតាំងនៅក្រសួងផែនការ ហើយស្ថិតនៅក្រោមការដឹកនាំរបស់សមាជិកអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

សមាជិក និងទីប្រឹក្សា ភ្នាក់ងារប្រតិបត្តិនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ដែលមានចែងឈ្មោះក្នុងប្រកាស ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-នីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស

### ប្រកាសលេខ ១៤៣ សហវ.ប្រក.ប

### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤/ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ តំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ